BMI0079

# សម្ភាសន៍ជាមួយឈ្មោះ រ៉េម គន់ ភេទប្រុស អាយុ៦៦ឆ្នាំ

មុខងាររសម័យខ្មែរក្រហមៈ ប្រធានកងភ្ជួរ

សព្វថ្ងៃរស់នៅភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០០:៥០:៥១

២២ទំព័រ

ដានីៈ អ៊ំអញ្ចឹងដឹបូងខ្ញុំសុំស្គាល់ឈ្មោះអ៊ំ តើឈ្មោះពេញរបស់អ៊ំឈ្មោះអីដែរ?

គន់ៈ ឈ្មោះរ៉េម គន់ ។

ដានីៈ អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

គន់ៈ អាយុ៦៦ឆ្នាំ ។

ដានីៈ អ៊ំសព្វថ្ងៃអ៊ំរស់នៅភូមិអីដែរភូមិហ្នឹង?

គន់ៈ ភូមិផ្គាំ ។

ដានីៈ ភូមិផ្គាំ ឃុំផ្គាំដែរ?

គន់ៈ បាទ!

ដានីៈ ស្រុកស្វាយចេក?

គន់ៈ បាទ!

ដានីៈ ខេត្តបន្ទាយមានជ័យ?

គន់ៈ ហ្នឹងអើយ ។

ដានីៈ ចុះអ៊ំអ្នកស្រុកកំណើតនៅណាដែរ?

គន់ៈ នៅហ្នឹង ។

ដានីៈ ចុះអ៊ំស្រី?

គន់ៈ នៅផ្គាំទាំងអស់គ្នា ។

ដានីៈ មានស្រុកកំណើតនៅផ្គាំហ្នឹងដែរ?

គន់ៈ បាទ!

ដានីៈ អ៊ំស្រីឈ្មោះអីដែរ?

គង់៖  ឈ្មោះ  ព្រីង  ជៀម ។

ដានី៖  អ៊ុំស្រីអាយុប៉ុន្មានហើយសព្វថ្ងៃ?

គង់៖  អាយុ៥៨ឆ្នាំ ។

ដានី៖  នៅផ្ដាំដែរ?

គង់៖  បាទ!

ដានី៖  អ៊ុំមានកូនចៅប៉ុន្មាននាក់ហើយ?

គង់៖  មានកូនចៅ៣នាក់ ។

ដានី៖  ស្រីប៉ុន្មាន  ប្រុសប៉ុន្មាន?

គង់៖  ប្រុស២នាក់  ស្រី១នាក់ ។

ដានី៖  ធំៗអស់ហើយ?

គង់៖  នៅមួយនៅរៀនថ្នាក់ទី១២ ។

ដានី៖  អញ្ចឹងនៅមួយដែលនៅរៀន  ហើយ២នាក់ទៀតការអស់ហើយ?

គង់៖  បាទ!

ដានី៖  អញ្ចឹងសល់តែ១នាក់ទេ?

គង់៖  បាទ!

ដានី៖  អ៊ុំប្រកបមុខរបររកស៊ីអីដែរ?

គង់៖  ធ្វើស្រែ ។

ដានី៖  ចុះឥលូវមានធ្វើអីទៀតទេ  មានធ្វើការរដ្ឋ  រាជការអីទេ?

គង់៖  ខ្ញុំសម្រាកហើយសព្វថ្ងៃនេះ  ធ្វើទាហាន ។

ដានី៖  ធ្វើទាហាន?

គង់៖  គេរំសាយហើយសព្វថ្ងៃនេះ  ទាហានគេរំសាយហើយ ។

ដានី៖  ចុះអ៊ុំកាលពីក្មេងអ៊ុំនៅស្រុកហ្នឹងដែរ?

គង់៖  នៅហ្នឹង ។

ដានី៖  ឪពុកម្ដាយអ៊ុំអ្នកនៅហ្នឹង?

គង់៖  បាទ!

ដានី៖  កាលពីមុនគាត់ធ្វើអីដែរ?

គង់៖  អត់មានធ្វើអីទេឪពុកម្ដាយខ្ញុំ  គាត់ធ្វើតែស្រែហ្នឹង ។

ដានីៈ ឪពុកអ៊ំឈ្មោះអីដែរ?

គង់ៈ ឈ្មោះ ជួន រ៉េម ។

ដានីៈ គាត់នៅដែរឬក៏ស្លាប់ហើយ?

គង់ៈ គាត់ស្លាប់អស់ហើយ ។

ដានីៈ គាត់ស្លាប់ពីអន្កាល់?

គង់ៈ ស្លាប់កាលឆ្នាំ៧៩ហ្នឹង ។

ដានីៈ ចុះម្ដាយឈ្មោះអី?

គង់ៈ ឈ្មោះមោះ ជុំ ។

ដានីៈ គាត់ស្លាប់ពេលណាដែរ?

គង់ៈ ឆ្នាំ៧៩ ។

ដានីៈ ឆ្នាំ៧៩ដែរ?

គង់ៈ បាទ!

ដានីៈ អ៊ំមានបងប្អូនប៉ុន្មាននាក់ដែរ?

គង់ៈ មាន៤នាក់ ។

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

គង់ៈ ស្រី២នាក់ ប្រុស២នាក់ ។

ដានីៈ អ៊ំកូនទីប៉ុន្មាន?

គង់ៈ ខ្ញុំកូនទី២ ។

ដានីៈ អ៊ំកាលពីក្មេងៗមានបានរៀនសូត្រដល់ណាដែរ?

គង់ៈ ខ្ញុំរៀនដល់ថ្នាក់ទី៨ចាស់ ។

ដានីៈ រៀននៅណាដែរ?

គង់ៈ រៀននៅសាលាផ្ដាំ ។

ដានីៈ ចុះអ៊ំឈប់រៀននៅឆ្នាំណា?

គង់ៈ ខ្ញុំឈប់ឆ្នាំ១៩៦៤ ហើយខ្ញុំបួស ។

ដានីៈ ឈប់រៀនហើយបួស?

គង់ៈ បាទ!

ដានីៈ បួសនៅវត្តណា?

គង់៖ បួសនៅវត្តផ្គាំ ។

ដានី៖ បួសបានប៉ុន្មានវស្សាដែរ?

គង់៖ បួសបាន៨ឆ្នាំ ។

ដានី៖ បួសបានយូដែរ?

គង់៖ បួសហ្នឹងទទួលខ្មែរក្រហមវៃចូលដល់នេះគេយកលោកទៅសឹកទៅ ។

ដានី៖ ឆ្នាំណា?

គង់៖ រំដោះឆ្នាំ៧៥ ខ្មែរក្រហមរំដោះទីនេះឆ្នាំ៧៥ ។

ដានី៖ អ៊ំបួសហ្នឹងឆ្នាំ១៩៦៨?

គង់៖ បាទ!

ដានី៖ ឆ្នាំ៦៨ហ្នឹងបួសបាន៨ឆ្នាំ អញ្ចឹង៦៨ហ្នឹង អញ្ចឹងបានន័យថាអ៊ំបួសឆ្នាំណា?

គង់៖ កាល៦៨ខ្ញុំរៀន ។

ដានី៖ អញ្ចឹងកាល៦៨នៅរៀននៅឡើយទេ?

គង់៖ ៦៨នៅរៀន ហើយ៦៩ហើយ៧០?

ដានី៖ ៧០រដ្ឋប្រហារហើយ?

គង់៖ រដ្ឋប្រហារបួស បួសហើយខ្មែរក្រហមរំដោះដីទីនេះ ។

ដានី៖ អញ្ចឹង?

គង់៖ ហ្នឹងអើយ ។

ដានី៖ អញ្ចឹងឆ្នាំ៦៨ឈប់ ហើយបួសឆ្នាំ៦៨ដែរ?

គង់៖ ហើយ៦៩,៧០ ។

ដានី៖ បាន៨ឆ្នាំខ្មែរក្រហមចូលមកទីនេះ?

គង់៖ បាទ! ព្រះចៅអធិការនេះអីសឹកអស់ ។

ដានី៖ ដល់ពេលសឹកហើយអ៊ំម៉េចទៀតទៅ?

គង់៖ ខ្ញុំធ្វើយុទ្ធជន ។

ដានី៖ ដល់ពេលសឹកហើយអ៊ំធ្វើយុទ្ធជនជាមួយខ្មែរក្រហម?

គង់៖ ខាងកម្ពុជាប្រជាធិបតេយ្យគេឲ្យយើងជាកងចល័ត ។

ដានី៖ អញ្ចឹងបន្ទាប់ពីសឹកហើយយើងចូលធ្វើកងយុទ្ធជន?

គង់៖ បាទ! គ្រប់រូបទាំងអស់គេឲ្យធ្វើយុទ្ធជនទាំងអស់គ្នា ។

ដានី៖ កាលហ្នឹងយើងស្ម័គ្រចិត្តឬក៏គេឲ្យយើងធ្វើ?

គង់៖ គេឲ្យយើងធ្វើ មានអ្នកណាហានស្ម័គ្រចិត្តកាលនោះ គេធ្វើយុទ្ធជនទាំងអស់គ្នាអ្នកណាក៏អត់មានសល់ដែរ ។

ដានី៖ យុទ្ធជនទាំងអស់គ្នា?

គង់៖ ហ្នឹងអើយ ធ្វើយុទ្ធជនដើម្បីគេយកកម្លាំងទៅធ្វើកងចល័ត ។

ដានី៖ ធ្វើយុទ្ធជនរយៈពេលប៉ុន្មានទៅបានឈប់?

គង់៖ ខ្ញុំបានគ្រួសារ ចាប់ដៃ ។

ដានី៖ ចាប់ដៃឆ្នាំណា?

គង់៖ ចាប់ដៃឆ្នាំណាទេ?

ដានី៖ ៧៥ពេលដែលគេបែកថ្មីៗហ្នឹង?

គង់៖ ទេ គេធ្វើក្រុមហើយឆ្នាំ៧៦ ចុងឆ្នាំ៧៥បានគេឲ្យចាប់ដៃគ្នា ។

ដានី៖ ចុងឆ្នាំ៧៥?

គង់៖ បាទ!

ដានី៖ រៀបការជាមួយអ៊ំស្រី រៀបការយ៉ាងម៉េចទៅ?

គង់៖ គេឈរចាប់ដៃគ្នា ។

ដានី៖ ប៉ុន្តែត្រូវគ្នាហើយពេញចិត្ត ឬក៏អង្គការរៀបឲ្យ?

គង់៖ អង្គការគេរៀបឲ្យ គេថាមិត្តឯងត្រូវយកមិត្តនេះអញ្ចឹងណា៎ ។

ដានី៖ កាលហ្នឹងអ៊ំអាយុប៉ុន្មាន?

គង់៖ អាយុប្រហែលជា២៥,២៦អីហ្នឹង ហើយប្រពន្ធខ្ញុំអាយុ១៦ ។

ដានី៖ ដល់ពេលអ៊ំរៀបការហើយយ៉ាងម៉េចទៅ?

គង់៖ រៀបការហើយគេបញ្ជូនទៅនៅចល័ត ។

ដានី៖ ការហើយគេបញ្ជូនទៅនៅចល័ត?

គង់៖ ប្រពន្ធខ្ញុំឲ្យនៅដាំបាយនេះ ហើយខ្ញុំទៅកាប់ឈើធ្វើផ្ទះឲ្យប្រជាជនថ្មី បំបែកគ្នាភ្លាមអត់ឲ្យនៅជិតគ្នាទេ បាននៅជាមួយគ្នាតែមួយយប់ប៉ុណ្ណោះ ស្គាល់គ្នាមិនទាន់ស្គាល់អស់ផង គេបំបែកយើងឲ្យទៅកាប់ព្រៃ ។

ដានី៖ ប្រពន្ធនៅកន្លែងដាំបាយ?

កង៖ ប្រពន្ធនៅកន្លែងដាំបាយ ហើយខ្ញុំទៅកាប់ឈើធ្វើផ្ទះមួយរយខ្នងសម្រាប់ប្រជាជនថ្មីមកនៅ ព្រៃយើងនេះកាលពីមុនសំបូរឈើណាស់ ។

ដានី៖ កាប់ឈើធ្វើផ្ទះឲ្យប្រជាជនថ្មី?

កង៖ បាទ!

ដានី៖ ហើយម៉េចទៀតទៅ?

កង៖ ដល់ពេលកាប់ឈើបានគេដឹកមក ហើយខ្ញុំធ្វើមេក្រុមចល័ត ។

ដានី៖ អ៊ំធ្វើមេក្រុមចល័ត?

កង៖ កូនក្រុម១០នាក់ មានអ្នកជួរ ហើយប្រពន្ធនោះដាំបាយ ហើយខ្ញុំគេឲ្យនៅចល័តនោះ ចល័តនៅភូមិស្វាយស នៅស្វាយសបានមួយខែទៅនៅព្រៃកចង្ហាររជើងគ្រោះទៅស្ទូង ភ្ជួរដីឲ្យគេស្ទូង នៅនោះបានប្រហែលជា៣,៤ខែ ។

ដានី៖ ហើយអ៊ំធ្វើអីទៅ កាលនៅជើងគ្រោះ?

កង៖ ភ្ជួរ កាន់មេក្រុមកូនក្រុមនោះឯង ក្នុង១០នាក់ហ្នឹងគេឲ្យយើងក្តាប់ទាំង១០នាក់ហ្នឹង ភ្ជួររាស់ ស្ទូឲ្យគេតម្រង់ជួរស្ទូង ។

ដានី៖ ហើយម៉េចទៀតទៅ?

កង៖ មកពីនោះវិញ ប៉ុន្តែត្រង់វាយ៉ាប់មនុស្សគ្រាន់តែលើកទំនប់ខ្ញុំឆ្លងពីនេះហួសទៅដល់ណាណី អានេះយុទ្ធជនមែនទេ លើកទំនប់វាក៏យ៉ាប់ ទំនប់ត្រពាំងថ្មយើងនេះ ខាងត្រពាំងថ្មវេទនាណាស់?

ដានី៖ កាលហ្នឹងពេលណាលើកទំនប់ត្រពាំងថ្មរហ្នឹង?

កង៖ ពេលសឹករួច ពេលសឹករួច ហើយខ្ញុំប្រពន្ធទៀតបានធ្វើនេះ គ្រាន់តែយុទ្ធជនដែកចល័តច្រើនចល័តទៅកាប់ ព្រៃចង្ហាររហូតប៉ុន្មានគីឡូប៉ុណ្ណោះ គ្រាន់តែមនុស្សវាវៃចោលជាង៣០នាក់ ។

ដានី៖ ម៉េចបានវៃចោល?

កង៖ អ្នកណាខ្ជិលគេឲ្យយកទៅរៀន គ្នាងងឹតមាន់ថាមែនងងឹតមាន់ គេថាគ្នាហ្នឹងខូចសតិអារម្មណ៍ហើយយកគ្នាទៅរៀនសូត្រនៅអន្តការ ដល់ឲ្យទៅរៀនសូត្របាត់ ហើយក្រុមយុទ្ធជនរបស់ខ្ញុំបាត់ឡើងរលោះបាត់១០០នាក់ជាង ហើយបានគេបំបែកឲ្យមកនៅនេះវិញ អានេះមកពីលើកអាងត្រពាំងថ្មហើយ នៅអាងត្រពាំងថ្មក៏ស៊ាប់មិនតិច មកដល់ទួលជើងគ្រោះក៏ស៊ាប់មិនតិចដែរ ។

ដានី៖ ចុះប្រធានគេកាលហ្នឹងគេមកក្តាប់អីលើយើង អ្នកស្រុកយើង?

កង៖ អត់ទេ គេមកពីខាងនារតីនោះហ្នឹង ។

ដានី៖ គេមកពីនារតី?

គង់៖ បាទ! ម៉ាសេរីសហករណ៍គេហ្នឹង បើពីមុននោះតាប៉ើយ ។

ដានី៖ តាប៉ើយហ្នឹងអ្នកមកពីណាម៉ោ?

គង់៖ តាប៉ើយហ្នឹងអ្នកក្នុងនេះឯង ដល់តាប៉ើយម៉ោបានតាសេរី ។

ដានី៖ តាប៉ើយអ្នកនៅណា?

គង់៖ តាប៉ើយអ្នកនៅព្រៃឈរ តែបាត់អស់ហើយ ។

ដានី៖ ព្រៃឈរនៅណា?

គង់៖ ព្រៃឈរយើងគ្រាសនេះ ។

ដានី៖ នៅក្នុងស្រុកស្វាយចេកយើងឬក៏នៅក្នុងស្រុកថ្មពួក?

គង់៖ នៅថ្មពួក ប៉ុន្តែមិនដឹងទៅណាបាត់ វាបាត់ត្រឹមនោះមកមិនដឹងទៅណាទេ ។

ដានី៖ ឆ្នាំណាបានតាសេរីគាត់មកគ្រប់គ្រង?

គង់៖ ឆ្នាំសេរីគ្រប់គ្រង?

ដានី៖ អឺការបានប៉ុន្មានឆ្នាំ?

គង់៖ អត់ទេសេរីមកក្រោយនេះទេ ។

ដានី៖ មកក្រោយ?

គង់៖ ហ្នឹងអើយសេរីមកជិតបែកហើយ ។

ដានី៖ កាលជំនាន់តាប៉ើយគាត់កាន់យ៉ាងម៉េចដែរ?

គង់៖ កាលហ្នឹងវាដូចតែគ្នា ម៉េចបានជាខ្ញុំថាដូចតែគ្នា ព្រោះដូចថាថ្ងៃនេះខ្វះធ្វើស្រែបានទាំងអស់ ធ្វើស្រែជាក្រុម ធ្វើស្រែទាំងអស់គ្នាអត់មានជម្រុកឯកជនទេកាលនោះ ប៉ុន្តែក្នុងនោះវាមិនឲ្យស៊ីគ្រប់ទេ ក្រុមខ្ញុំមួយក្រុម៤០នាក់ ប្រជាជនរួម៤០នាក់វាឲ្យតែ៤កំប៉ុងទេ ។

ដានី៖ ៤កំប៉ុងហូបអីគ្រាន់ គ្នាដល់ទៅ៤០នាក់ហើយហូបម៉េចគ្រាន់គ្នា ។

គង់៖ ម៉េចបានគ្រាន់បើសុទ្ធតែទឹកទទេហ្នឹង យើងមកពីធ្វើការគឺមានតែទឹកទទេ បើនិយាយគ្មានអ្នកណាសូវជឿទេ ព្រោះគេសព្វថ្ងៃគេស្រួល ហើយសព្វថ្ងៃនេះដែលខ្ញុំបានរស់ព្រោះខ្ញុំតស៊ូខ្លាំងណាស់ វេទនាណាស់ វេទនាមែនទែនណាស់ ។

ដានី៖ អញ្ចឹងកាលជំនាន់តាប៉ើយហ្នឹងក៏ពិបាកដែរ?

គង់៖ ពិបាក អត់មានទេចាប់ពីបំបែកធ្វើស្រែក្រុមរួចយ៉ាប់រហូត រហូតមកដល់សេរីនេះបានជាពិបាកអានោះគេទៅនៅចល័តគេនោះ កាលហ្នឹងពីបីជំនាន់ ។

ដានី៖ សេរីហ្នឹងអ្នកនៅនារតីមក?

គង់៖ បាទ!

ដានី៖ មកពីខេត្តណាកាលហ្នឹង?

គង់៖ មិនដឹងមកពីខេត្តណាទេ ។

ដានី៖ តាប៉ើយហ្នឹងប្រធានអីគេ?

គង់៖ តាប៉ើយនោះខាងសេរី តែគេឲ្យថាធ្វើលេខាកាលហ្នឹង ។

ដានី៖ សេរីហ្នឹងគាត់ប្រធានអីកាលហ្នឹង?

គង់៖ សេរីប្រធានសហករណ៍ ។

ដានី៖ ប្រធានសហករណ៍ហ្នឹងស្មើនឹងប្រធានអី?

គង់៖ ប្រធានសហករណ៍ស្មើមេឃុំ ។

ដានី៖ ប្រធានសង្កាត់?

គង់៖ បាទ!

ដានី៖ ចុះមុនតាប៉ើយ មុនតាសេរីហ្នឹងពីណាគេ?

គង់៖ មិនដឹងពីណាទេ បើកាលហ្នឹងចល័តហើយមិនដែលបាននៅស្រុកទេ គេចល័តពីត្រពាំងថ្មីទៅដើង មកពីដើងគ្រោះគេចល័តនេះទៅនោះទៀតហើយ គេចេះតែបញ្ជូនទៅគេចល័យយុទ្ធជនហ្នឹងឯង ។

ដានី៖ ចុះប៉ុន្មានខែប៉ុន្មានឆ្នាំទៅបានជួបប្រពន្ធកូនម្តង?

គង់៖ មិនបានជួបទេ គេនៅផ្សេងទៅហើយខ្ញុំនៅផ្សេងទៅ ខ្ញុំទៅនៅចល័តស្វាយស ហើយនេះអាង យើងនេះវាអាសារផាប់ណាស់ ហើយបាត់បង់ច្រើន គេវ៉ៃចោលអាណាវាឥឡូវបន្តិចគេវ៉ៃចោល ហើយខ្ញុំចេះតែទ្រាំទៅ ចេះតែស៊ូទៅព្រោះយើងធ្លាប់ស៊ីក្តាមស៊ីអីយើងអាចធន់បាន តែគ្នាប្រជាជនថ្មីគ្នាមិនដែលពីបីថ្ងៃបាត់ខ្លួន ។

ដានី៖ អញ្ចឹងស្លាប់ច្រើនមែនទេ?

គង់៖ អ៎ស្លាប់ច្រើនណាស់ វាអស់ហ្នឹងអា៧៦,៧៧នេះឯង គ្រាន់តែវាយកទៅវ៉ៃចោលអស់៤៩ គ្រួសារហើយហ្នឹង ខ្ញុំឃើញវេទនានោះបានច្បាស់ គេយកទៅវ៉ៃនោះវ៉ៃទាំងវេទនាណាស់ ពោះ គ្រប់ខែហើយហ្នឹងហើយវ៉ៃគ្នាឈាមរហាតៗ គ្រប់ខែថ្ងៃនេះឯងគេយកទៅវ៉ៃចោល ទាំងប្តីទាំង កូនទាំងប្រពន្ធ ។

ដានី៖ ម៉េចបានដាគេយកទៅវ៉ៃចោល?

កង់៖ បើញនិយាយរួមទៅពួកអានេះវាយួន វាថាជាប់ខ្សែយួនជាប់ខ្សែទាហាន វាថាមានមេការ ដូចពួកខ្មោចតាឈឿន ខ្មោចតាសុន យ៉ាងរាប់ច្រើនណាស់ក្នុងនេះសុទ្ធតែ៤៩គ្រួសារដែលគេយកមកវៃចោលនៅគោកខ្មោចនេះ ។

ដានី៖ ភូមិគោកខ្មោចអាហ្នឹង?

កង់៖ អត់មានភូមិអីទេ ។

ដានី៖ ក្នុងឆ្នាំយើងនេះដែរ?

កង់៖ បាទ!

ដានី៖ អ៊ំមានបានឃើញទេ?

កង់៖ អត់មានបានឃើញគេវៃទេ ដល់ពេលគេវៃរួចហើយបានខ្ញុំទៅមើល ។

ដានី៖ ទៅមើលឃើញខ្មោចទេ?

កង់៖ ខ្មោចគេកប់ក្រោយ ឃើញតែដំបង រទេះយកមកវិញទាំងអស់ ។

ដានី៖ ខោអាវអីម៉េច?

កង់៖ ខោអាវដាក់ហិបយកមកវិញទាំងអស់ កាលនោះជំនាន់សេរីសហករណ៍ ។

ដានី៖ ហើយសេរីជាអ្នកបំបាត់វិទ្យាល័យ?

កង់៖ បំបាត់សេរីវិទ្យាល័យទេ តែសេរីជាប្រធានសហករណ៍ ។

ដានី៖ ចុះអ្នកដែលសម្លាប់ច្រើនតែជាសហករណ៍ឬអ្នកណាមកពីណាមក?

កង់៖ ពួកកងទ័ពយើង ។

ដានី៖ ពួកកងទ័ពណា?

កង់៖ ពួកកងទ័ពខ្មែរក្រហមនេះ គេយកកងទ័ពមកឃុំ គេប្រុងសម្លាប់ភូមិនេះឯង កងទ័ពគេបញ្ជូនមកពីភូមិភាគក្នុងភូមិជិតអស់ បានគេញែកមកនេះហើយបានគេឲ្យរទេះនេះទៅ គេប្រាប់ថាមិត្តឯងត្រូវទៅនៅភ្នំស្រុក ផ្លាស់ទៅនៅភ្នំស្រុកផ្ទះថ្មផ្ទះថ្មីអីណា ឲ្យបរទេះគោជ្រូកហើយស្អីក៏ដោយឲ្យតែមានបងប្អូនស្លាប់ ចាប់មាន់ចាប់ទាបំពង ប៉ុណ្ណេះឯងចេញ ហើយដល់ពេលដែលទៅដល់ភ្នំខ្មោចខ្ញុំមានបងប្អូនស្លាប់ ។

ដានី៖ ឆ្នាំប៉ុន្មាន?

កង់៖ ដូចជាចុងឆ្នាំហើយ ឆ្នាំ៧៩ ។

ដានី៖ ចុងហើយ?

កង់៖ កាលហ្នឹងវៃទោសទាំងអស់ កាលហ្នឹងគេវៃភូមិភាគទាំងអស់ នៅថ្មពួកក៏មានគេវៃទៀត ។

ដានី៖ ចុះប្រជាជនមូលដ្ឋានអត់អីទេ?

គង់៖ អត់អីទេ អ្នកមូលដ្ឋានដែរតែកុំតែមានជាប់ភាពទិន្នាការ

ដានី៖ ទាល់តែមានជាប់ភាពទិន្នាការ?

គង់៖ អ្នកឯងធ្វើទាហានលន់ នល់ហើយនឹងសិទ្ធ សិទ្ធវៃនៅនេះ ហើយគេវៃចោលទាំងអស់ ស្លាយសល់តែប្រឡោះ ។

ដានី៖ ចុះគេម៉េចដឹងថាយើងធ្វើអីៗ?

គង់៖ គេគ្រាន់តែយកការមកច្បាស់មកនិយាយ ព្រោះកាលហ្នឹងគេជម្លៀសលោកគ្រូមក សួគេមកពីថ្មពួមាន១៦នាក់មានពេទ្យមានអី គ្មានរស់ទេរស់បានតែ២នាក់ ។

ដានី៖ ២នាក់?

គង់៖ រឿនមួយវាទាហានហើយវានៅសៀមរាប ។

ដានី៖ អាហ្នឹងពីណាគេអ្នករាយការណ៍ប្រាប់ថាអ្នកណាធ្វើអីៗ?

គង់៖ អត់ដឹងទេ ។

ដានី៖ ចុះប្រធានកងអីខាងណាជាអ្នកគ្រប់គ្រង?

គង់៖ គ្មានប្រធានកងទេ បើយុទ្ធជនបានមានប្រធានកង មានតែសហករណ៍ ។

ដានី៖ សហករណ៍?

គង់៖ បើក្រុមយុទ្ធមានមេកង ។

ដានី៖ ចុះមេភូមិ?

គង់៖ មេភូមិដូចជាអត់មានទេ មានតែមេក្រុម មេក្រុមក្តាប់៤០នាក់ក្នុងមួយរោងបាយយើងរហូតដល់១៣ក្រុមនោះ ហើយកាន់កាប់ខាងហូបបាយ តែបើសិនជាមេកងវិញខ្ញុំត្រូវក្តាប់ខុទាហរណ៍ថាខ្ញុំត្រូវក្តាប់១០០នាក់ជុំគ្នាទៅជាកម្លាំងធំមួយ ។

ដានី៖ ចុះកាលហ្នឹងគេឲ្យធ្វើប្រធានក្រុម?

គង់៖ ខ្ញុំធ្វើប្រធានក្រុមបានប៉ុន្មានថ្ងៃ មិនមែនមេកងទេមេក្រុមក្តាប់ជួរ បើមេកងគេក្តាប់យុទ្ធជន កងរបស់ខ្ញុំមិនបានធ្វើយុទ្ធទេ គេប្រើសុទ្ធសាទ ដល់បានប្រពន្ធនេះគេឲ្យធ្វើមេក្រុម មេក្រុមបានប្រហែលជា ម៉ាចល័តដើងគ្រោះរួចឈ្មោះរឹងអស់សិទ្ធ ។

ដានី៖ ហើយម៉េចទៀតទៅ?

គង់៖ បើមិត្តវាលំបាកជាងគេសព្វបែបយ៉ាងទាំងអស់ ក្រោយពីសេរីហ្នឹងទៅ មានអាកូរ ។

ដានី៖ កាលសម្លាប់៤៩គ្រួសារហ្នឹងជិនាន់សេរី?

គង់៖ បាទ!

ដានី៖ ចុះជំនាន់កូរនេះ?

គង់៖ អារកក្បួយខ្ញុំអញ្ចេះ គាត់មេក្រុម ប៉ុន្តែហ្នឹងអ្នកដេញបាញ់ឈ្មោះ តារីនៗគាត់អារក ។

ដានី៖ ម៉េចបានគាត់អារក?

គង់៖ មានរឿងអី មុនដំបូងខ្ញុំខុសសិលធម៌ ដល់ពេលខុសសិលធម៌អញ្ចឹងគេបញ្ជូនខ្ញុំឲ្យទៅនៅថ្មពួក ត្រឹម មួយអាទិត្យបានអង្គការបានបញ្ជូនអាកូនក្មេងមកឲ្យធ្វើទាន្និការ ហើយខ្ញុំទ្រាំមិនបានខ្ញុំក៏រត់ទៅ ។

ដានី៖ មកធ្វើអី?

គង់៖ រត់ចូលពេទ្យ ។

ដានី៖ ឆ្នាំណាហ្នឹង?

គង់៖ ជិតហើយ កាលនោះយួនវ៉ៃចូលភ្នំពេញហើយ ថ្ងៃនេះយើងចុងកន្ទុយយើងនៅសល់ ហើយដូចអាពួកនេះអាហ្នឹងវាធ្វើកងមួយតែពួកវារត់ចេញខ្លះហើយ ។

ដានី៖ ចុះកាលហ្នឹងគេចោទអ៊ំថាខុសសិលធម៌?

គង់៖ យើងស្រលាញ់គ្នា ហើយគេមិនឲ្យស្រលាញ់គ្នាទេដល់ពេលយើងស្រលាញ់គ្នាគេថាយើងហ្នឹងខុសសិលធម៌ហើយគេយកខ្ញុំនេះទៅវ៉ៃចោល ។

ដានី៖ អ៊ំស្រលាញ់គ្នាជាមួយពីណាគេ?

គង់៖ ងាប់ហើយសព្វថ្ងៃនេះ មិនបានទៅស្រលាញ់គ្នាអី គ្រាន់តែនៅជាមួយគ្នាតាមចល័ត ទំនាក់ទំនងគ្នាស្រីហើយនឹងប្រុសគ្រាន់តែនិយាយគ្នាខ្លះអញ្ចឹងទៅហើយគេថាយើងហ្នឹងស្រលាញ់គ្នា ។

ដានី៖ តែអ៊ំស្រលាញ់គ្នាមែនឬក៏អត់ទេ?

គង់៖ មិនមែនស្រលាញ់គ្នាទេ សម័យនោះមានអ្នកណាហ៊ាននិយាយជាមួយស្រី ខ្ញុំចេះតែនិយាយពីណាពីណីទៅហើយគេប្រកាន់ក៏យកខ្ញុំទៅ ខ្ញុំជាប់គុកបាន៣ថ្ងៃ ។

ដានី៖ ជាប់គុកនៅណា?

គង់៖ ជាប់គុកនៅថ្មពួក ។

ដានី៖ ម៉េចទៅកាលហ្នឹងគេតាមដានម៉េច?

គង់៖ កាលហ្នឹងខ្ញុំរត់ចូលព្រៃ ។

ដានី៖ ធ្វើម៉េចបានជាអ៊ំរត់រួច?

គង់៖ គេមិនទាន់បានជួសជុលគុកទេគេគ្រាន់តែដាក់ឲ្យយើងនៅហើយ ហើយគេចាប់អង្គការទៅរៀននៅនោះ អង្គការមកបានគេរៃយើងចោល គេនៅចាំខ្ញុំនៅខាងក្រៅ៣ថ្ងៃ ដល់ពេលបានថ្ងៃខ្ញុំរត់កាត់ព្រៃកាត់អី ហើយដេកព្រៃអត់មានបានបាយបានអីហូបពេញមួយថ្ងៃ ។

ដានី៖ អញ្ចឹងគេចាប់តែអ៊ីម្នាក់ទេអញ្ចឹង?

គង់៖ អត់ទេគេចាប់ដល់ទៅ៣,៤នាក់នោះ ។

ដានី៖ គេចាប់ទាំងអស់៤នាក់ ទាំងស្រីទាំងប្រុស?

គង់៖ បាទ! ទាំងស្រីទាំងប្រុស ។

ដានី៖ យុទ្ធតែស្រីហើយនឹងប្រុស?

គង់៖ មានសហករណ៍ខុសសិលធម៌ដែរ សហករណ៍នោះឈ្មោះតាអ៊ុយ ។

ដានី៖ ហើយរត់មកភូមិវិញឬក៏រត់ទៅណា?

គង់៖ រត់មកភូមិវិញ ។

ដានី៖ អាហ្នឹងឆ្នាំ៧៩ហើយហ្នឹង?

គង់៖ បាទ! កាលហ្នឹងមានប៉ាវ៉ាចុះមកខ្លះ ។

ដានី៖ ហើយម៉េចទៀតទៅដល់ពេលអញ្ចឹង?

គង់៖ ខ្ញុំរត់មកនៅព្រៃ នៅព្រៃបានប្រហែលជា៦,៧ខែហើយសន្តិភាព នៅព្រៃប្រហែលជា៤,៥នាក់អាខ្លះស្លាប់ព្រោះខ្មែរក្រហមបាញ់ស្លាប់ ។

ដានី៖ អញ្ចឹងអ៊ំនៅព្រៃហ្នឹងមិនមែននៅជាមួយខ្មែរក្រហមទេ?

គង់៖ អត់ទេ ។

ដានី៖ អញ្ចឹងនៅជាមួយពីណាគេ?

គង់៖ នៅជាមួយគ្នាឯងហ្នឹង ។

ដានី៖ ចុះម៉េចបានអត់នៅភូមិ?

គង់៖ សន្តិភាពហើយ ។

ដានី៖ សន្តិភាពពេល៧៩ហើយហ្នឹង?

គង់៖ ៧៩ហើយ ។

ដានី៖ ហើយម៉េចពេលសន្តិភាពហើយអត់មកនៅភូមិ?

គង់៖ ម៉ោតើ! ម៉ោទាំងអស់គ្នា គេបញ្ជូនទៅនេះក៏គេមកចូលភូមិ ខ្ញុំទៅនោះទៅខ្ញុំចូលមកនេះមកជួបជុំប្រពន្ធកូន ។

ដានី៖ កាលហ្នឹងអ៊ំមានកូននូវ?

គង់៖ អត់មានទេ ។

ដានី៖ កាលហ្នឹងអត់ទាន់មានទេ?

គង់៖ បាទ!

ដានី៖ កាលហ្នឹងសន្តិភាពហើយណោះ?

គង់៖ បាទ! សន្តិភាពហើយ ។

ដានី៖ ដល់ពេលអ៊ំមកនៅជួបជុំប្រពន្ធកូនវិញហើយអ៊ំទៅព្រៃវិញឬក៏ម៉េច?

គង់៖ អត់ទេ ចប់នៅធ្វើស្រែធ្វើចំការរហូត ។

ដានី៖ អ៊ំធ្វើស្រែធ្វើចំការ?

គង់៖ បាទ!

ដានី៖ ចុះអ៊ំអត់មានធ្វើប៉ារ៉ាធ្វើអីទេ?

គង់៖ អត់មានធ្វើទេ មិនដែលបានអាវប៉ារ៉ាពាក់បានមួយដងទេ ។

ដានី៖ ខាងខ្មែរក្រហមក៏មិនដែលដែរ?

គង់៖ អត់ដែលទេ ខ្ញុំធ្វើតែរដ្ឋកម្ពុជាទេ ។

ដានី៖ ធ្វើរដ្ឋកម្ពុជា ធ្វើទាហាន?

គង់៖ បាទ! ធ្វើទាហាន ។

ដានី៖ អ៊ំចូលធ្វើទាហានឆ្នាំណា?

គង់៖ ឆ្នាំ៩២ ។

ដានី៖ ឆ្នាំ៩២បានចូលធ្វើទាហាន?

គង់៖ បាទ!

ដានី៖ ម៉េចបានជាឆ្នាំ៩២ហើយបានចូលធ្វើទាហាន?

គង់៖ កាលឆ្នាំ៨៦ខ្ញុំធ្វើនរគបាលឃុំ ។

ដានី៖ កាល៨៦អ៊ំធ្វើនរគបាលឃុំ?

គង់៖ បាទ! ហើយទៅនៅរៀនបាត់ដំបងវគ្គទី២ហ្នឹងមួយវគ្គ រៀនមុខជំនាញផ្នែកបច្ចេកទេសមួយវគ្គ ហើយបន្ទាប់បានខ្ញុំមកនៅនេះ ។

ដានី៖ ធ្វើនៅណា?

គង់៖ ធ្វើអនុនរគបាលឃុំ ។

ដានី៖ ធ្វើអនុនរគបាលឃុំនៅណា?

គង់៖ ធ្វើនៅភ្នាំយើងនេះ ។

ដានី៖ ធ្វើដល់ឆ្នាំ៩២យើងនេះ?

គង់៖ បាទ!

ដានី៖ ហើយម៉េចបានដាប្តូរពីនរគបាលឃុំមកធ្វើជាទាហានវិញ?

គង់៖ ថាមូលហេតុវាអញ្ចឹងឯង សម័យតាពិនមកនៅនេះខ្ញុំឈប់ធ្វើនរគបាលឃុំមកចូលធ្វើនៅបន្ទប់លេខ១គេផ្លាស់ កាលនៅរដ្ឋកម្ពុជាគេហៅនរគបាលឃុំបន្ទប់លេខ១ ។

ដានី៖ អាហ្នឹងឆ្នាំប៉ុន្មាន ឆ្នាំ៩២មែន?

គង់៖ មុនឆ្នាំ៩២ទៀត ហើយកាលហ្នឹងតាពិនមកនៅប៉ុន្មានឆ្នាំ ហើយខ្ញុំមិនដឹងថាតាពិនហ្នឹងមេ ព្រោះឃើញគាត់នៅផ្ទះហ្នឹង គាត់រកស៊ីតាពិនហ្នឹងមកតាមរយៈអាខេងនេះឯង មកពីកប្បាសមក គាត់ស្គាល់ខ្មែរក្រហមគ្នាគាត់ៗមក ពិសេសតាស្រឿន ។

ដានី៖ ឌុល សារឿន?

គង់៖ បាទ! មកតាមខ្សែឌុល សារឿនហ្នឹងឯង ហើយខ្ញុំមិនដឹងថាតាឌុចនេះធ្វើអីនោះទេ ដឹងតែគាត់មកពីកោកកប្បាសមក មកតាមគ្នានេះឯង ។

ដានី៖ គាត់មកឆ្នាំណា?

គង់៖ ខ្ញុំចាំមិនបានទេ ។

ដានី៖ មកមុនអ៊ុន គាត់ចូលមែន?

គង់៖ អ៊ុន គាត់មកហើយ ។

ដានី៖ គាត់មកដឹបូងអឹធ្វើបន្ទុកឃុំហើយបានគាត់មកមែនទេ?

គង់៖ បាទ!

ដានី៖ គាត់មកគាត់ទាក់ទងតាមឃុំតាមអីដែរ?

គង់៖ គាត់ទាក់ទង តែគាត់ទាក់ទងតាមឃុំ ហើយកាលគាត់មកនោះវាវល់វេកមិនដឹងអាណាអាណីទេ វាមិនដែលបានពិនិត្យពិច័យអីទេ ហើយគេចេះតែផ្តាច់ខ្លួនចូលមក គេផ្តាច់ខ្លួនហើយខ្មែរក្រហមចេះតែផ្តាច់ខ្លួនចូលមក គេបាញ់គ្នាប៉ុងប៉ាំងគេដាក់កាំភ្លើងសារភាពមកចរចាគ្នា ហើយគេពាក់តែមេដៃទៅ ហើយពីថ្ងៃបីថ្ងៃគេធ្វើទៀតទៅ ។

ដានី៖ ចុះកាលនោះកាលជិតនាំឆ្នាំ៨៦ហើយអ៊ំធ្វើនរគបាលឃុំអីហ្នឹងម៉េចដែរ ដូចថាប្រទាញប្រទង់ជូនទៅខាងរដ្ឋកម្ពុជា ជូនទៅខាងខ្មែរក្រហម?

គង់៖ បាទ! ក្នុងនេះលំបាកខ្ញុំជាងគេ ខ្ញុំហើយនឹងខ្មោចអាធននេះចាប់ចងខ្ញុំយកទៅវ៉ៃចោល វាប្រុង យកខ្ញុំទៅវ៉ៃចោលពីបីសារ ។

ដានី៖ ម៉េចបានជាគេប្រុងយកអ៊ំទៅវ៉ៃចោល?

គង់៖ បាយ! ចាំមើលតាស្រៀន១០០នាក់ ហើយពួកអាបីសាមនោះតែ៣០នាក់ទេ ។

ដានី៖ បីសាមហ្នឹងពីណាគេ?

គង់៖ អាបីសាមហ្នឹងពួកខ្មែរក្រហមខ្ញុំដាក់ឈ្មោះឲ្យវា អាហ្នឹងគេតាមសាខាគេ ប៉ុន្តែខ្ញុំទទួលបាយកញ្ចប់ បាន១០០ហើយតែនៅខ្វះ៣០នាក់ហ្នឹង ដល់ហើយគេមកអូសកខ្ញុំយកទៅវ៉ៃចោល ព្រោះខ្ញុំ ទទួលបាយឲ្យគេអត់បាន ទទួលទៅដល់ចុងភូមិនោះមានបងប្អូនលើកដុះ ក៏យកបាយគេនោះមកឲ្យ ឲ្យវាទៅក៏រួចខ្លួន កុំអីខ្ញុំស្លាប់ពេលនោះហើយ ។

ដានី៖ ពួកខ្មែរក្រហមដែលចូលមកដែរ?

គង់៖ ពួកខ្មែរក្រហមចូលមកសុំបាយ ។

ដានី៖ យើងធ្វើឃុំអញ្ចឹងទាល់តែរកបាយឲ្យគេ?

គង់៖ រកបាយរកទឹកឲ្យគេខ្វះទៅណា ធ្វើម៉េចបើវាគៀបនៅជុំវិញ ចាប់ពីពេលនោះទៅខ្ញុំមិនដែលនៅទេ ខ្ញុំតាមតែវៀតណាម បើវៀតណាមទៅនៅទ្រាសខ្ញុំទៅនៅទ្រាស បើវៀតណាមទៅនៅភូមិត្បូង ខ្ញុំទៅនៅភូមិត្បូង អត់ដែលហ៊ាននៅទេ គិតទៅវ៉ៃខ្មែរក្រហមខ្ញុំចេះវ៉ៃដូចជាទាហាន ដូចតែស្រុក ដូចតែកងទ័ព ព្រោះមេឃុំនៅបន្ទប់យើងមួយនេះ នរគបាលឃុំនេះដើរវ៉ៃគ្រប់តែគ្នា ខ្លាំងនៅ ឯណាយើងទៅវ៉ៃ ព្រោះយើងមានកម្លាំងកាន់អាវុធតាំងពី៨៥,៨៦មក ។

ដានី៖ ចុះតាពិនមកហ្នឹងអ៊ំគ្រាន់តែដឹងថាគាត់មកតាមរយៈខ្មែរក្រហមឈ្មោះខេង ហើយនឹងតាសារឿន ហ្នឹងទេ?

គង់៖ បាទ!

ដានី៖ ប៉ុន្តែអត់ដឹងថាឆ្នាំណាគាត់មកទេ?

គង់៖ ខ្ញុំមិនច្បាស់ទេ ហើយខ្ញុំវាភ្លេចផង ។

ដានី៖ គាត់មកនៅណា ផ្ទះគាត់នៅឯណា?

គង់៖ ផ្ទះគាត់នៅនោះ ។

ដានី៖ ចុះប្រពន្ធគាត់ឈ្មោះអី?

គង់៖ ឈ្មោះយាយម៉ៅ ខ្ញុំមិនសូវដឹងច្បាស់ទេព្រោះខ្ញុំមិនសូវដែលបានទាក់ទងផង ។

ដានី៖ ចុះកាលហ្នឹងឃើញគាត់មានកូនចៅប៉ុន្មាននាក់ដែរកាលគាត់មកនៅ?

គង់៖ ឃើញមានកូន៣នាក់ ។

ដានី៖ គាត់រកស៊ីអីគេកាលមកនៅហ្នឹង?

គង់៖ ធ្វើគ្រូបង្រៀន ។

ដានី៖ គាត់ធ្វើគ្រូបង្រៀន?

គង់៖ ហ្នឹងអើយ!

ដានី៖ ចុះប្រពន្ធគាត់ធ្វើអី?

គង់៖ អត់មានធ្វើអីទេ គ្រាន់តែដាក់ម៉ាស៊ីន ។

ដានី៖ ដាក់ម៉ាស៊ីនអីគេ?

គង់៖ ម៉ាស៊ីនកិនស្រូវ ។

ដានី៖ មានម៉ាស៊ីនកិនស្រូវទៀត?

គង់៖ បាទ!

ដានី៖ ចុះគាត់មានលក់ដូរអីទេ?

គង់៖ អត់មានលក់ដូរអីទេ ។

ដានី៖ គាត់មកនៅបានប៉ុន្មានឆ្នាំបានចោរប្លន់?

គង់៖ មកនៅបានប្រហែលជា២ឆ្នាំ ខ្ញុំមិនសូវចាំខែថ្ងៃផង ។

ដានី៖ ហើយកាលប្លន់ហ្នឹងអ៊ំដឹងទេ?

គង់៖ ខ្ញុំនៅនេះឯង ខ្ញុំនៅដេកនេះហើយកូនវារត់មករកខ្ញុំនៅនេះ ។

ដានី៖ រត់មកធ្វើម៉េច?

គង់៖ ថាឲ្យខ្ញុំទៅជួយ ហើយខ្ញុំថាទៅជួយម៉េចកើតអាអូន មិនស្រួលហ្នឹងគេបាញ់ហើយ នៅនេះហើយ បើឯងរត់ផុតហើយនៅនេះហើយ នៅជុំអញនេះហើយ អាមួយធាត់ណាស់ ។

ដានី៖ កាលគេប្លន់ប្រពន្ធគាត់ហ្នឹងប្រហែលជាម៉ោងប៉ុន្មាន?

គង់៖ ប្រហែលម៉ោង៨ ។

ដានី៖ ម៉ោង៨យប់?

គង់៖ បាទ! ដូចជាមិនទាន់ល្ងាចទេព្រោះខ្ញុំយកឈ្លបទៅដាក់នោះរួចហើយខ្ញុំបកមកវិញមកដេក មានបានសម្រាកណាព្រោះយាមរាល់តែថ្ងៃ ហើយក៏មកដេកដល់ពេលមកដេកចំអាថ្ងៃនោះ ទើបតែសំងំបានបន្តិច ឈ្លបមាននៅនេះណាឈ្លបត្រូវយាមមុខសញ្ញាខ្ទាំងនៅនោះ ខ្ទាំងវាបែរបន្ទាយខ្ញុំទៅឈរចាំបន្ទាយនៅនោះ ហើយមានដាក់ឈ្លបនៅនេះបានជាមានឈ្លបមានអី ។

ដានី៖ ចុះកាលនោះគេប្តូនបានអីពីគាត់ខ្លះ?

គង់៖ មិនដឹងទេ ។

ដានី៖ អ៊ំអត់ដឹងទេ?

គង់៖ គ្មានបានអីនោះទេបើតាមគេរាយការណ៍ ព្រោះឃើញគាត់មិនដែលមានស្អីផង ។

ដានី៖ អត់ដែលឃើញមានអីទេ?

គង់៖ ហ្នឹងអើយ ប៉ុន្តែគាត់នេះបើតាមនេះពួកទ័ពគេដេញ ព្រោះគាត់ធ្វើបាបគេ ហើយពួកស្រុកនេះគេធានាយក ។

ដានី៖ ចាប់ពីណាគេ?

គង់៖ ចាប់ពួកតាពិននេះឯង ចាប់យកទៅធ្វើបាបនៅខាងលិចនោះ ។

ដានី៖ ចាប់ពីអន្លង់?

គង់៖ ចាប់មុនប្តូននេះ ។

ដានី៖ ម៉េចបានជាគេចាប់?

គង់៖ វាមិនដឹងរឿងណា៎ ព្រោះពួកទ័ពប៉ារ៉ា ។

ដានី៖ ពួកទ័ពប៉ារ៉ាគេចាប់?

គង់៖ ហ្នឹងអើយ ។

ដានី៖ ពីណាអ្នកធានាមក?

គង់៖ ពួកតាង៉ាតនេះធានាតាហ្នឹងមកវិញ ។

ដានី៖ ម៉េចបានជាគេចាប់គាត់?

គង់៖ មិនដឹងរឿងទេ គេដេញហើយគេថាគាត់ធ្វើអីកាលពីដើម តែខ្ញុំមិនដឹង ។

ដានី៖ ពួកប៉ារ៉ាចាប់គាត់?

គង់៖ ពួកប៉ារ៉ា ។

ដានី៖ ចាប់មុនគេប្តូនគាត់?

គង់៖ ហ្នឹងអើយ ។

ដានី៖ ចាប់មុនយូទេ?

គង់៖ ចាប់មុនពីរខែបីខែមុននេះ ។

ដានី៖ ទៅប្តូនហ្នឹងម៉េចប្រពន្ធគាត់គេបាញ់ស្លាប់?

គង់៖ គេបាញ់ស្លាប់ ។

ដានីៈ ចុះគាត់គេបាញ់ដែរអត់?

គង់ៈ គេថាចាក់ មានបាញ់ណា ។

ដានីៈ ចុះប្រពន្ធគាត់?

គង់ៈ ប្រពន្ធគាត់ដូចជាចាក់ ខ្ញុំមិនសូវដឹងដែរព្រោះព្រឹកឡើងខ្ញុំត្រូវទៅរៀន ភ្លឺឡើងអត់មានបានធ្វើអីទេ គេហៅទៅរៀន ឲ្យទៅរៀននៅស្វាយចេកណា ហើយអត់មានបានរបាយការណ៍អីឲ្យគេ ដល់ហើយមេឃុំគេធ្វើរបាយការណ៍ទៅឲ្យ បើមេឃុំប្រហែលគេបានត្រួតពិនិត្យត្រឹមត្រូវ ភ្លឺឡើងនោះប្រុយខ្ញុំ ។

ដានីៈ ចុះតាពិនម៉េចទៅ?

គង់ៈ មិនដឹងទេ ។

ដានីៈ ពេលគាត់ត្រូវរបួសគេដឹកគាត់ទៅពេទ្យដែរ?

គង់ៈ ទៅពេទ្យហ្នឹងមានតែកូនចៅគាត់ជំនាញទេដែលយកទៅពេទ្យ ។

ដានីៈ បាទ!

គង់ៈ ខ្ញុំអត់មានបានឃើញទេ ព្រោះព្រឹកឡើងមានការងារគេហៅទៅរៀន មានតែមេឃុំគេមើលបាន គេមានរបាយការណ៍ តែខ្ញុំអត់មានបានរបាយការណ៍អីទេ ។

ដានីៈ ដល់ហើយទៅតាពិនគាត់មករស់នៅហ្នឹងវិញឬក៏ម៉េច?

គង់ៈ អត់ទេ ពេលដែលគាត់ជាហើយគាត់ទៅរស់នៅស្វាយចេក ។

ដានីៈ ពេលដែលជាហើយគាត់ទៅនៅស្វាយចេក?

គង់ៈ បាទ! គាត់នៅស្វាយចេកបានប៉ុន្មានខែទេហើយរត់ទៅទៀត ។

ដានីៈ រត់ទៅណាទៀត?

គង់ៈ រត់ទៅប៉ោយប៉ែត ឮថាពេលដែលគេចាប់បានហ្នឹងចាប់បាននៅប៉ោយប៉ែត នៅនេះបានប៉ុណ្ណាហើយទៅនៅស្វាយចេកបានប្រហែលមួយឆ្នាំបែបប្រហែលមិនដល់ផងរត់ទៅទៀត ។

ដានីៈ ចុះខ្ញុំឮថាកាលហ្នឹងគេចោទប្រកាន់អ៊ំទាក់ទងរឿងហ្នឹងអ៊ំម៉េចដែរកាលហ្នឹងអ៊ំ?

គង់ៈ ខ្ញុំបដិសេធព្រោះខ្ញុំមិនដឹងរឿង ឡើងទៅដល់តុលាការហើយខ្ញុំនិយាយទៅ តាមដានទៅ ចុះមកស្រាវជ្រាវទៅ ដល់ពេលស្រាវជ្រាវចុះឡើងៗបានប្រហែលជាមួយពីរខែខ្ញុំលក់ស្វាយ ហើយស្រាវជ្រាវអីមិនបានដូចតែគ្នា មិនដឹងអីព្រោះខ្ញុំមិនដឹងមែន ។

ដានីៈ កាលហ្នឹងគេចោទអ៊ំយ៉ាងម៉េចអ៊ំអាចជួយរៀបរាប់បានទេ?

គង់ៈ គេថាខ្ញុំនេះទៅប្តូន់គេ ។

ដានី៖ ថាទៅប្ចូន់តាពិនហ្នឹង?

គង់៖ ហ្នឹងអើយ ។

ដានី៖ ពីណាគេអ្នកចោទ?

គង់៖ មិនដឹងថាអ្នកណាអ្នកចោទទេ មេឃុំបើនិយាយគឺមេឃុំ ។

ដានី៖ មេឃុំអ្នកចោទ?

គង់៖ ហ្នឹងអើយ ហើយបានតែប៉ុន្មានខែខ្ញុំត្រលប់មកវិញមេឃុំក៏ងាប់ទៅ ។

ដានី៖ ចុះកាលហ្នឹងរបាយការណ៍ថាអ៊ីអ្នកប្ចូន់ហ្នឹងមេឃុំអ្នកធ្វើ?

គង់៖ បាទ! មេឃុំអ្នកធ្វើ ។

ដានី៖ កាលហ្នឹងមេឃុំហ្នឹងយ៉ាងម៉េចគាត់ត្រូវរ៉ូវជាមួយអ៊ីដែរប្ញក៏យ៉ាងម៉េច?

គង់៖ គាត់បងប្អូនប្រពន្ធខ្ញុំនេះឯង ប៉ុន្តែគាត់មិនសូវស៊ីចង្វាក់ម៉េចទេគាត់ហ្នឹង ។

ដានី៖ កាលហ្នឹងគេចោទអ៊ីថាអ្នកប្ចូន់តាពិនហ្នឹង?

គង់៖ មិនដឹងទេ ។

ដានី៖ គេចោទថាអញ្ចឹង?

គង់៖ បាទ!

ដានី៖ គេចោទហើយយ៉ាងម៉េចទៀតទៅអ៊ី?

គង់៖ មិនដឹងទេ មិនដែលបានដឹងថារបាយការណ៍ថាយ៉ាងម៉េចទេ គេសួរកខ្ញុំ ហើយខ្ញុំមិនបានធ្វើអីខ្ញុំមិនខ្លាចទេ ។

ដានី៖ ចុះប្ចូន់ហើយបានប៉ុន្មានថ្ងៃបានគេចោទអ៊ី?

គង់៖ អត់ទាន់បាន១០ថ្ងៃទេ វាគ្មានភស្តុតាងអីនឹងថាកើតទេ អ្នកថាចេះតែថា ដូចខ្ញុំថាមកធ្វើអីនេះប្រហែលជាមករកអីហើយអាហ្នឹងគ្រាន់តែស្មានអញ្ចេះទេ វាមិនមានភស្តុតាង មិនមានសាក្សីទេ មិនដឹងអ្នកណាសាក្សី អ្នកថាចេះតែថា ខ្ញុំមិនសុខចិត្តទេ ។

ដានី៖ ចុះកាលហ្នឹងគ្នាប៉ុន្មាននាក់?

គង់៖ តាមខ្សែបណ្តោយយោធាទេ ។

ដានី៖ អ៊ំតាមខ្សែបណ្តោយយោធាទេ ។

គង់៖ តាឡាយ ស្រអែមសព្វថ្ងៃ ហើយម្សិលមិញខ្ញុំបានជួបគាត់ ។

ដានី៖ តាឡាយ ស្រអែមហ្នឹងគាត់អ្នកមកនាំខ្លួនអ៊ីទៅ?

គង់៖ ហ្នឹងអើយ ។

ដានី៖ កាលហ្នឹងនាំតែខ្លួនម្នាក់ទេប្ញក៏មានពីណាគេទៀត?

គង់៖ ហ្នឹងអើយ កាលហ្នឹងគេមានធ្វើអីគេគ្រាន់តែថាឲ្យយកប៉ិចយកសៀវភៅទៅរៀនស្វាយ ហើយប្រជុំ ប្រជុំនៅស្វាយចេក ដល់ពេលទៅឃើញឡានគេមកហើយគេឲ្យខ្ញុំឡើងឡាន ហើយខ្ញុំក៏ថាអីយ៉ាបានជិះឡានហើយ បានទៅប្រជុំបានឡានជិះ ស្រាប់តែទៅដល់នោះគេដោះប្រវ៉ាក់កិបតែម្តង ។

ដានី៖ គេដាក់ប្រវ៉ាក់អ៊ំទៀត?

គង់៖ ហ្នឹងអើយ ហើយខ្ញុំថាម៉េចក៏ចង ខ្ញុំមានសិទ្ធសេរីភាព ហេតុអីបានជាអ្នកឯងមកចាប់ខ្ញុំ ខ្ញុំមានរឿងអី ។

ដានី៖ គេថាអ៊ំទៅប្ញូន់តាពិនហ្នឹង?

គង់៖ ហ្នឹងអើយ ។

ដានី៖ ហើយចុះគេមានវ៉ៃអ៊ំដែរ?

គង់៖ មិនបានវ៉ៃទេ គ្រាន់ថាវាអស្ចារ្យខ្លួនឯង បើនេះខ្ញុំចងកងាប់បាត់ហើយតែខ្ជិល ធ្វើការតាំងពីណាពីណើមកមិនដែលបន្តរឿង មានតែខំកសាងខ្លួនតាំងពីបដិវត្តិរហូតមកដល់សព្វថ្ងៃហើយ សុខចិត្តក្រមិនដែលបានរស់ស្អីនឹងគេទេ ស៊ីញ៉ៅគេយក១០បាត ហើយ១រៀលពីររៀលខ្ញុំមិនដែលយកផង ធ្វើការដើម្បីជួយជាតិមានមែន ។

ដានី៖ កាលហ្នឹងគេនាំខ្លួនអ៊ំទៅតែម្នាក់ឯង ប្ញក៏គេនាំខ្លួនអ្នកផ្សេងទៅដែរ?

គង់៖ អត់ទេ តែម្នាក់ឯងគត់ ។

ដានី៖ តែម្នាក់ឯងទេ?

គង់៖ បាទ!

ដានី៖ ទៅស្វាយក៏ម្នាក់ឯងដែរ?

គង់៖ ទៅម្នាក់ឯង មិនដឹងថាអ្នកណាមិនដឹងទៅចោទអ្នកណាបានទេ ។

ដានី៖ គេនាំខ្លួនអ៊ំទៅបានប៉ុន្មានបានគេដោះលែងខ្លួនអ៊ំមកវិញ?

គង់៖ ពីរខែ ។

ដានី៖ ពីរខែ?

គង់៖ ដូចជាមួយខែជាងទេ ។

ដានី៖ គេអត់មានយកអ៊ំទៅដាក់ព័ន្ធធានាគារអីទេ?

គង់៖ គេដាក់ខ្នោះមួយយប់ដែរ ។

ដានី៖ ដាក់ខ្មោះមួយយប់ហើយយ៉ាងម៉េចទៀត?

គង់៖ ភ្លឺឡើងគេដោះឲ្យយើងធ្វើការធម្មតា ប៉ុន្តែអានោះក្នុងភូមិគេ យើងអត់មានសិទ្ធសេរីភាពធ្វើការឲ្យគេ ។

ដានី៖ នៅកន្លែងយោធាមិនមែននៅកន្លែងគុកទេ?

គង់៖ នៅកន្លែងយោធា ។

ដានី៖ កន្លែងយោធាកន្លែងស៊ុបគេហ្នឹង?

គង់៖ បាទ!

ដានី៖ រយៈពេលជិតពីខែ?

គង់៖ បាទ!

ដានី៖ រយៈពេលពីខែបានគេប្រលែងមកវិញ?

គង់៖ បាទ! ដល់ពេលប្រលែងមកវិញគ្មាននៅផ្ទះទេ អ្នកស្រុកខ្ញុំធ្វើទាហាន ។

ដានី៖ ដល់ពេលអ៊ំមកវិញអ៊ំធ្វើទាហាន?

គង់៖ មិនបានមកដល់ផ្ទះទេ ខ្ញុំធ្វើទាហាននៅនោះ ។

ដានី៖ ធ្វើទាហាននៅណា?

គង់៖ នៅស្រុកស្វាយចេក ។

ដានី៖ នៅស្រុកស្វាយចេក?

គង់៖ ធ្វើទាហានស្រុក ។

ដានី៖ ទាហានស្រុកខាងរដ្ឋកម្ពុជា?

គង់៖ បាទ!

ដានី៖ ម៉េចបានអ៊ំធ្វើទាហាន?

គង់៖ ខ្ញុំធ្វើដល់ណាណីនោះ អញ្ចឹងខ្ញុំធ្វើអ្នកស្រុកមិនកើតទេ ។

ដានី៖ ខ្មាស់គេ?

គង់៖ ខ្មាស់គេ មកវិញមកធ្វើអ្នកស្រុកខ្មាស់គេណាស់ សុខចិត្តធ្វើទាហានវៃខ្ញាំងឲ្យងាប់ល្អមើលជាងជួយជាតិ ព្រោះខ្ញុំជាអ្នកជួយជាតិយូណាស់មកហើយ បានប្រាក់ខែ៧០ ។

ដានី៖ ហើយអ៊ំទៅនៅស្វាយចេកដល់ពេលណាបានអ៊ំត្រលប់មកស្រុកវិញ?

គង់៖ ខ្ញុំអាសាមកតែញ៉ុកហ្នឹង ។

ដានី៖ ឆ្នាំណាបានអ៊ំមកនៅស្រុកវិញឈប់ទៅនៅនោះ ។

គង់ៈ គេចប់អស់ខ្លាំង ហើយខ្ញុំនៅតែបន្ទាយស្វាយចេកហ្នឹង មកធ្វើស្រែ មកស្ទូងហើយគេហៅទៅវិញ ។

ដានីៈ អ៊ំចូលនិវត្តិបានប៉ុន្មានឆ្នាំហើយ ។

គង់ៈ អត់ទាន់បាន២ឆ្នាំទេ ។

ដានីៈ អត់ទាន់បាន២ឆ្នាំទេ?

គង់ៈ បាទ!

ដានីៈ ចុះរឿងករណីតាពិនហ្នឹងដល់ពេលគេប្រលែងអ៊ំមកក៏ចប់ទៅអត់មានអីពាក់ព័ន្ធទៀតទេ?

គង់ៈ អត់មានទេ ។

ដានីៈ ស្ងាត់ទៅ?

គង់ៈ បាទ! ដល់ពេលគេកាត់ទោសតាពិននេះបានខ្ញុំភ្ញាក់ ខ្ញុំថាអ៊ំតាពិនខ្លាំងសម្លាប់គេអស់រាប់ម៉ឺននាក់ ខំដាន់ឯងអារឿងសម្លាប់ តែតាមពិតគេសម្លាប់អស់រាប់ម៉ឺនណោះ ខ្ញុំគិតឃើញអញ្ចេះទេ មានតែខ្ញុំទេមិនសូវចិត្ត បើគេឲ្យកាត់ទោសខ្មែរក្រហមអីមិនចង់ឃើញវេទនាមនុស្សដែលស្លាប់ ។

ដានីៈ ចុះអ៊ំដល់ពេលក្រោយនេះពេលដែលគេកាត់ទោសតាពិនអ៊ំភ្ញាក់ម៉េចទៅ អ៊ំមានអារម្មណ៍យ៉ាងម៉េចដែរ?

គង់ៈ អារម្មណ៍ខ្ញុំថាតិច ។

ដានីៈ តិច?

គង់ៈ បាទ!

ដានីៈ ម៉េចបានតិច?

គង់ៈ ម៉េចបានតិចបើគាត់សម្លាប់មនុស្សអស់រាប់ម៉ឺននាក់ ប៉ុន្មានពាន់នាក់ វារាងតិច មិនសូវពេញចិត្ត ប៉ុន្តែបើខ្ញុំឃើញសេចក្ដីសំគាល់ថាឲ្យកូនចៅចេះអធ្យាស្រ័យគ្នានេះ ខ្ញុំអស់អីនិយាយហើយរឿងគេធ្វើបាបខ្ញុំមករហូត ខ្ញុំដេកស្រម៉ៃថាតាមដំណើរទៅអធ្យាស្រ័យឲ្យកូនចៅក្រោយៗទៅ ។

ដានីៈ អញ្ចឹងអ៊ំគិតថាដោយសារគេចោទប្រកាន់អ៊ំថាអ៊ំជាអ្នកប្ដូរហ្នឹង អ៊ំគិតថាតាពិនហ្នឹងជាអ្នករាយការណ៍ប្រាប់គេឬក៏ម៉េច?

គង់ៈ មិនដឹងដែរ និយាយរួមទៅមិនដឹងថាមេឃុំជាអ្នកចោទឬក៏តាពិនជាអ្នកចោទទេ ស្រាប់តែគេនាំខ្ញុំទៅ តែខ្ញុំមិនដែលបានស្រាវជ្រាវទេ ។

ដានីៈ ប៉ុន្តែអ៊ំមានសង្ស័យទេ?

គង់៖ អត់មានសង្ស័យទេ ខ្ញុំមិនដែលសង្ស័យថាអ្នកណាចោទខ្ញុំ ខ្ញុំមិនដែលសង្ស័យមិនដែលស្រាវជ្រាវរកទេ ខ្ញុំថាចាំមើលទៅអ្នកណាត្រង់ក៏រស់ទៅហើយអ្នកណាវៀចក៏ងាប់ទៅ ។

ដានី៖ ដល់ពេលក្រោយមកអ៊ំឃើញគេកាត់ទោសតាពិនអីហ្នឹង ថាគេកាត់ទោសហ្នឹងនៅតិចទៀត?

គង់៖ ខ្ញុំគិតថាវាងតិចព្រោះគាត់សម្លាប់មនុស្សអស់ច្រើន ហើយកាត់វាងតិច ។

ដានី៖ អញ្ចឹងអ៊ំគិតថាតុលាការដែលគេបង្កើតឡើងសម្រាប់កាត់ទោសមេដឹកនាំជាន់ខ្ពស់ហើយតាពិនហ្នឹងអ៊ំគិតថាវាត្រឹមត្រូវដែរឬទេ?

គង់៖ វាត្រឹមត្រូវហើយ តែចំពោះខ្លួនខ្ញុំនេះទេដែលគិតថាវាងតិច វាមិនអស់ចិត្តដូចដែលគេធ្វើបាបយើងណា៎ ស៊ីបបរមួយវែកហើយក្បាលជង្គង់ដើរមិនរួចណា ស៊ីស្រូវហើយអកស្រូវហើយចាប់ក្នាយកទៅចងទៀតដូចវាមិនសម តាមដែលគេធ្វើបាបយើងរហូតមកដល់សព្វថ្ងៃនេះហើយកាត់ទោសប៉ុណ្ណឹង កាលខ្ញុំរស់នៅក្នុងសម័យខ្មែរក្រហមវេទនា ហើយគ្រាន់តែយើងនិយាយស៊ីសស៊ូសជាមួយស្រីក៏គេប្រកាន់យើងថាយើងខុសសិលធម៌យកយើងទៅសម្លាប់ចោល ។

ដានី៖ អញ្ចឹងអ៊ំដោយសារឥឡូវវាងយប់ហើយអញ្ចឹងខ្ញុំអរគុណអ៊ំច្រើនដែលបានសំណេះសំណាលជាមួយខ្ញុំទាក់ទងនឹងជីវិតរបស់អ៊ំ ហើយនឹងរឿងរ៉ាវរបស់តាពិននេះអញ្ចឹងខ្ញុំសូមអរគុណអ៊ំច្រើន ។

គង់៖ បាទ!

«ចប់»